# I - រាជរដ្ឋាភិបាល

១៣៨

## ១_អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៤៩ អនក្រ.បក

១៤០ ស្ដីពី

### ការកែសំរួលអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់

[illegible]

មាត្រា ១ .- ត្រូវបានកែសំរួលនូវបទបញ្ញត្តិមួយចំនួននៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរំលាយនិងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងមាត្រា ដូចខាងក្រោម ÷

**១_មាត្រា ២ថ្មី :**

**ក_អំពីផ្លូវជាតិ :**

១_ ផ្លូវជាតិលេខ ១ ពីព្រំដែនបាវិត មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : បាវិត (ខេត្តស្វាយរៀង) ។

២_ ផ្លូវជាតិលេខ ២ ពីព្រំដែនភ្នំដិន មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : ភ្នំដិន (ខេត្តតាកែវ) ។

៣_ ផ្លូវជាតិលេខ ៤ ពីក្រុងព្រះសីហនុ មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : កំពង់ផែ ពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ ។

៤_ ផ្លូវជាតិលេខ៥ ពីព្រំដែនប៉ោយប៉ែត មកដល់រាជធានីភ្នំពេញមាន០១ ចំណុចៈ ប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ) ។

**ឃ_អំពីផ្លូវសមុទ្រ :**

១_ ខេត្តកោះកុងមាន ០៤ចំណុចៈ កោះស្តេច ប៉ាក់ខ្លង ចាំយាម និងស្រែអំបិល។

២_ ក្រុងព្រះសីហនុមាន ០៣ចំណុច : កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ ទំនប់រលក និងស្ទឹងហាវ ។

៣_ ខេត្តកំពតមាន ០២ចំណុច : ទាន់ហាន់ និងកោះសេះ ។

៤_ ទីក្រុងកែបមាន ០១ចំណុច : ផែក្រុងកែប ។

**២_មាត្រា ៣ថ្មី :**

៣_ ច្រកទ្វារតំបន់ព្រំដែន

ខេត្តកំពត

_ ទាន់ហាន់

_ កោះសេះ

ខេត្តកោះកុង
- កោះស្តេច (ផែ)
- ប៉ាក់ខ្លង (ផែ)
- ស្រែអំបិល

មាត្រា ២ .- ជំនួសអោយទីស្នាក់ការដែលបានរំសាយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសហការនឹងក្រសួងពាក់ព័ន្ធ ពង្រឹងប្រព័ន្ធត្រួតពិនិត្យរៀងៗខ្លួននៅតាមច្រកចេញចូលតាមព្រំដែន ដែលបានកំណត់រួចហើយ ។

មាត្រា ៣ .- ក្នុងករណីចាំបាច់មានគ្រោះអាសន្នកើតឡើង ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនប្រទេសទ្វេភាគី និងច្រកទ្វារតំបន់ព្រំដែនមានសិទ្ធិស្នើសុំកំលាំងនគរបាលព្រំដែន និងកងរាជអាវុធហត្ថជាតិ ដែលបោះទីតាំងនៅជិតបំផុតអោយចូលមកជួយធ្វើអន្តរាគមន៍ ។

មាត្រា ៤ .- បទបញ្ញត្តិទាំងឡាយក្រៅពីការកែសំរួលខាងលើ ហើយដែលមានចែងក្នុងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរំសាយនិងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅជាធរមានដដែល ។

មាត្រា ៥ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ប្រចាំក្រុងកែប ប្រចាំក្រុងប៉ៃលិន និងអភិបាលគ្រប់ខេត្ត_ក្រុង ត្រូវទទួលបន្ទុកអនុវត្ត

អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា ហត្ថលេខានិងត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

* * *

## អនុក្រឹត្យ លេខ ៥០ អនក្រ.បក

## ស្តីពី

## ស្តីពីការបង្កើតគណៈកម្មការជាតិ ដើម្បីសិទ្ធិមនុស្ស

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ផ្អែកតាមស្ថានភាពវិវត្តន៍និងចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា